Asian Health Services
818 Webster Street
Oakland, CA 94607

CEO MESSAGE

អ្នកជម្ងឺ និង មិត្តភក្តិជាទីស្រឡាញ់រាប់អាន,

នេះជារយៈពេលសាមញ្ញបំផុតដែលភាគច្រើននៃពួកយើងយល់ព្រមច្រាស្រ័យទាក់ទងជាមួយគ្រូពេទ្យរបស់យើង, ធ្វើធ្មេញ, ឬស្វែងរកការប្រឹក្សាយោបល់ពេលយើងមានជម្ងឺធ្លាក់ទឹកចិត្ត, រាងនៅតែស្ថិតជាឧបសគ្គដ៏ធំសម្រាប់សហគមន៍របស់យើងចំពោះអ្នកមានភាពលំបាកផ្នែកភាសា, វប្បធម៌, និងហិរញ្ញវត្ថុ។ ដោយការពិនិត្យមើលតម្រូវការរបស់អ្នកជម្ងឺរបស់យើង,យើងប្តេជ្ញាបន្តធ្វើការដោយពុំនៀមហត់ប្តោះទៅរកបេសកម្ម ២របស់យើង ដោយផ្តល់ការវិវឌ្ឍទាំសុខភាពដែលមានគុណភាព និងផ្តល់សិទ្ធិបញ្ជោះតម្លៃដល់អ្នកជម្ងឺរបស់យើង ដើម្បីធានាថាតម្រូវការនៃការវិវឌ្ឍទាំសុខភាពដែលគ្មានដំណោះស្រាយត្រូវបានដោះស្រាយ។

កាលពីឆ្នាំកន្លងទៅនេះ, យើងធ្វើការបានយ៉ាងច្រើន។ ដោយទទួលបានជោគជ័យក្នុងការចុះឈ្មោះអ្នកជម្ងឺដែលគ្មានធានារ៉ាប់រងសុខភាពរាប់ពាន់ នាក់ទៅក្នុងគំរោងធានារ៉ាប់រងសុខភាព។ ដើម្បីបំពេញតម្រូវការទៅតាមកំណើនប្រជាជនរបស់ជនជាតិអាស៊ីអាមេរិកាំង និងជនជាតិដែលរស់នៅលើកោះអាស៊ីចាំស៊ីហ្វិក, យើងបានបន្ថែមផ្នែកឯកទេសខាងសុខភាព ផ្លូវចិត្តថ្មីមួយទៀត។ យើងកំពុងសាងសង់កន្លែងពេទ្យធ្មេញថ្មីមួយទៀតដែលគ្រោងនឹងបើកនៅឆ្នាំ២០១៧។ ជាមួយគ្នានេះដែរយើងបានទទួលអំណោយសប្បុរសពីម្ចាស់ជំនួយអនាមិកម្នាក់ដើម្បីពង្រីកផ្នែកកុមារ និងកន្លែងថែទាំបន្ទាន់ដែលត្រូវការជាចាំបាច់សម្រាប់កុមារ, យុវជន និងក្រុមគ្រួសារទាំងឡាយដែលមានប្រាក់ចំណូលតិច។

តាមរយៈការផ្លាស់ប្តូរនិងការពង្រីកនេះ,យើងនៅតែរក្សាការប្តេជ្ញាចិត្តផ្តល់ដល់អ្នកជម្ងឺរបស់យើងនូវសេវាវិវឌ្ឍទាំសុខភាពដែល មានគុណភាព។

អរគុណ

ស៊ែរី ហៀរ៉ូតា

នាយកប្រតិបត្តិ

ASIAN HEALTH SERVICES

ព្រឹត្តិប័ត្រមន្ទីរសុខភាពអាស៊ី

818 WEBSTER STREET, OAKLAND, CA 94607

ផ្នែកឯកទេសសុខភាពផ្លូវចិត្តថ្មី

ដោយបណ្ឌិត ចច រ៉ុង ជានាយកផ្នែកឯកទេសសុខភាពផ្លូវចិត្ត

ការស្វាគមន៍ពីមន្ទីរសុខភាពអាស៊ីដល់ផ្នែកឯកទេសខាងសេវាសុខភាពផ្លូវចិត្តថ្មី!
ថ្មីៗនេះមន្ទីរសុខភាពអាស៊ីបានពង្រីកកម្មវិធីសេវាសុខភាពផ្លូវចិត្ត ដែលរួមបញ្ចូលទាំងផ្នែកឯកទេសសុខភាពផ្លូវចិត្ត។ តាំងពីថ្ងៃទី១ ខែកក្កដាឆ្នាំ២០១៦ មន្ទីរសុខភាពអាស៊ីបានផ្តល់សេវាសុខភាពផ្លូវចិត្ត ដល់អតិថិជនដែលមានមេឌីខែលនៅក្នុងស្រុកអាឡាមេដា។

ក្តីសង្ឃឹមរបស់យើងគឺដើម្បីបង្កើនការទទួលបានសេវាសុខភាពផ្លូវចិត្ត នៅក្នុងសហគមន៍របស់ជនជាតិអាស៊ីអាមេរិកាំង, និងកាត់បន្ថយការមាក់ងាយដែលនៅតែមាននៅជុំវិញស្ថានភាពសុខភាពផ្លូវចិត្ត។កុមារ, យុវជន និង មនុស្សពេញវ័យដែលជួបប្រទះនឹងជម្ងឺផ្លូវចិត្តពីស្ថានភាពមធ្យម ទៅធ្ងន់ធ្ងរអាចទទួលបានសេវាសុខភាពផ្លូវចិត្ត ដែលរួមមាន: ធ្វើការវាយតម្លៃជម្ងឺ, ដោះស្រាយបញ្ហា, ការប្រឹក្សា, ត្រប់ត្រង់រឿង, ការអន្តរាគមន៍ពេលវិបត្តិ, ធ្វើយ៉ាងបទ្ទូរស័ព្ទពេលអាសន្ន, ការការពារ និងអប់រំ, ការជួយឧបត្ថម្ភ, ការគាំទ្រនិងផ្តល់សេវាបញ្ជូន។ យើងសហការជាមួយអ្នកផ្តល់សេវាផ្នែកវេជ្ជសាស្ត្រ និងទន្តសាស្ត្រនៃមន្ទីរសុខភាពអាស៊ី។ បុគ្គលិករបស់យើងនិយាយពីភាសា និងមានវប្បធម៌ពីរដូចជា ភូមា, ចិនកាតាំង, ជប៉ុន, យ៉ាអ៊ុន, ខ្មែរ, កូរ៉ា, ចិនកុកង៉ី, មៀន, ថាហ្គាឡុក, វៀតណាម និង អង់គ្លេស។ យើងមានទីតាំងនៅអាគារលេខ ៣១០ ផ្លូវលេខ១៨, បន្ទប់លេខ២០០A។ សូមទូរស័ព្ទមកយើងដែលមានលេខ ៥១០_៣៣៥_៣៩០០ សម្រាប់ព័ត៌មានបន្ថែមទៀត ឬដើម្បីកំណត់នៃការណាត់ជួប។

យើងសង្ឃឹមរង់ចាំបំរើលោកអ្នក, មនុស្សជាទីស្រឡាញ់របស់អ្នក និង សហគមន៍របស់យើង។

នៅក្នុងការចេញផ្សាយនេះ

ទំព័រ 1
- ផ្នែកឯកទេសសុខភាពផ្លូវចិត្តថ្មី

ទំព័រ 2
- សារៈសំខាន់នៃដែនការវិវឌ្ឍទាំសុខភាព
- រដូវផ្តាសាយធំបានមកដល់ហើយ!

ទំព័រ 3
- ការពង្រីកមន្ទីរពេទ្យធ្មេញក្នុងឆ្នាំ២០១៧
- ការបើកការចុះឈ្មោះសម្រាប់ឆ្នាំ២០១៧ បានមកដល់ហើយ
- ហេតុអ្វីបានជាយើងទាមអស់គ្នាគួរតែចុះឆ្នោតនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៦

ទំព័រ 4
- CEO Message

សារ:សំខាន់នៃផែនការថែទាំសុខភាព

ដោយផេទីណា មួយ, វេនឌី ង៉ែ, យនទី ធេង, ជានាយកក្រុមប្រឹក្សាគិតាល
ផេជ្ជបណ្ឌិត ចច លី, ជាប្រធានផ្នែកវេជ្ជសាស្ត្រ

<u>តើអ្វីទៅជាផែនការថែទាំសុខភាព?</u>

ផែនការថែទាំសុខភាពគឺជាឯកសារ ដែលធ្វើឲ្យអ្នកជ្រើសរើសការថែទាំសុខភាពដោយខ្លួនឯង បើសិនជាអ្នកមានជម្ងឺធ្ងន់ធ្ងរ។
ឧទាហរណ៍: ឯកសារនេះអនុញ្ញាតិឲ្យអ្នកជ្រើសរើសអ្នកណាម្នាក់ឲ្យសម្រេចចិត្តលើផែនការថែទាំសុខភាព និងបំណងប្រាថ្នាជំនួសអ្នក
ប្រសិនបើអ្នកមិនមានសមត្ថភាពក្នុងការសម្រេចចិត្តដោយខ្លួនឯងបានដោយសារតែជម្ងឺ ឬការរងរបួស។ អ្នកអាចជ្រើសរើសយកការអន្តរាគមន៍
នៃការថែទាំសុខភាពដែលអ្នកចង់បាន។ អ្នកមានសិទ្ធិលប់ចោល ឬប្តូរផែនការថែទាំសុខភាពនេះបានគ្រប់ពេល។

<u>តើហេតុអ្វីបានជាវាមានសារ:សំខាន់?</u>

ផែនការថែទាំសុខភាពនេះកំណត់គោលដៅពីបំណងប្រាថ្នានៃការថែទាំសុខភាពរបស់អ្នកពីសុខភាពល្អ ទៅការបង្កើតភាពសុខស្រួលនៅដំណាក់ចុងក្រោយនៃជីវិតតាមរបៀប ធម្មជាតិ។ ឯកសារដែលមានប្រសិទ្ធិភាពជួយអ្នកកំណត់ដែលអ្នកបានជ្រើសរើសជាអ្នកជំនួយរបស់អ្នក។ ដោយការចែករំលែកផែនការសុខភាពដ៏មានតម្លៃ និងសេចក្តីសង្ឃឹមជាមួយកំណាងរបស់អ្នក, អ្នកនឹងអាចប្រើយោបល់ដ៏ល្អបំផុតរបស់ពួកគាត់ ដោយតម្រូវតាមកាល:ទេស: ទៅតាមបំណងប្រាថ្នាដែលអ្នកចង់បានជាទីបំផុត។
ការបំពេញឯកសារផែនការថែទាំសុខភាពនេះ នឹងជួយការម្មណ៍ទទួលខុសត្រូវ និងវិប្បដិសារីនៅក្នុងចំណោមក្រុមគ្រួសារ និងមិត្តភក្តិដើម្បីធ្វើឲ្យការសម្រេចចិត្តបានល្អបំផុតសម្រាប់ការថែទាំសុខភាពរបស់អ្នក។

<u>តើអ្វីដែលមន្ទីរសុខភាពអាស៊ីនឹងផ្តល់ជូនអ្នកជម្ងឺរបស់យើង?</u>

<u>ការផ្លាស់ប្តូររបស់គ្លីនិក:</u> មន្ទីរសុខភាពអាស៊ីបានចាប់ផ្តើមផ្តល់ពត៌មានអំពីផែនការថែទាំសុខភាពចាប់តាំងពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១៦ សម្រាប់អ្នកជម្ងឺដែលមានអាយុចាប់ពី៣០ឆ្នាំឡើងទៅ និងជំរុញឲ្យពួកគាត់បំពេញទម្រង់បែបបទដែលពាក់ព័ន្ធ។ មានទម្រង់បែបបទពីរដែលត្រូវបំពេញ។ ឯកសារទាំងនោះមានជាភាសា កូមា, ចិន, អង់គ្លេស, ខ្មែរ, កូរ៉ូ, ម៉ុងហ្គូលី, ថាហ្គាឡុក, និង វៀតណាម។ សូមពិភាក្សាជាមួយគ្រូពេទ្យរបស់អ្នក បើសិនជាអ្នកមានសំណួរអ្វី ក្នុងនាមជាអ្នកផ្តល់សេវាសុខភាពរបស់អ្នក, យើងចង់ធ្វើឲ្យប្រាកដថាបំណងប្រាថ្នារបស់អ្នកត្រូវបានអនុវត្តន៍។ បើសិនជាអ្នកចង់,គ្រូពេទ្យរបស់អ្នកអាចធ្វើការណាត់ឲ្យអ្នកជួបជាមួយបុគ្គលិកខាងសុខភាពផ្លូវចិត្តរបស់យើងដែលអាចជួយអ្នកបំពេញទម្រង់បែបបទផែនការថែទាំសុខភាពនេះ។ ទោះជាយ៉ាងណាក็ដោយត្រូវចាំថា ផែនការថែទាំសុខភាពដែលមានប្រសិទ្ធិភាពតម្រូវការប្រាស្រ័យទាក់ទងគ្នារវាងអ្នក, ជាមួយក្រុមគ្រួសារ និងគ្រូពេទ្យរបស់អ្នក ដូច្នេះអ្នកអាចរាល់គ្នានឹងយល់ពីបំណងប្រាថ្នារបស់អ្នក។

<u>វគ្គអប់រំ:</u> មន្ទីរសុខភាពអាស៊ីកំពុងស្វែងរកវិធី ដើម្បីផ្តល់ឲ្យសិក្ខាសាលាសម្រាប់ការសាបន្ថែមទៀត ដែលអាចផ្តល់ការអប់រំនិងជាជំនួយសម្រាប់ ផែនការថែទាំសុខភាព ។ យើងនឹងឲ្យអ្នកជម្ងឺដឹងនៅពេលដែលមានវគ្គអប់រំនេះនៅពេលខាងមុខ ។

រដូវផ្តាសាយធំបានមកដល់ហើយ!

ជាទូទៅមេរោគវីរុសរបស់ជម្ងឺផ្តាសាយធំកើតរាលដាល ចាប់ពីចុងរដូវស្លឹកឈើជ្រុះ ដល់ដើមរដូវផ្តាវីក។ អ្នកដែលប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់គឺអ្នកដែលមានជម្ងឺកំពុងវិវត្តធ្ងន់ធ្ងរ ឬមានរហូតដល់ស្លាប់សម្រាប់កុមារដែលមានវ័យក្មេង, ស្ត្រីមានផ្ទៃពោះ, មនុស្សដែលមានវ័យចំណាស់ និងអ្នកដែលមានជម្ងឺរ៉ាំរ៉ៃ។
នៅពេលដែលមកជួបគ្រូពេទ្យអ្នកលើកក្រោយ, សូរគាត់អំពីឬំចាក់បង្ការរោគផ្តាសាយធំនេះ។

តើត្រូវធ្វើដូចម្តេចដើម្បីការពារខ្លួនរបស់អ្នក ?

ទទួលការចាក់ឬំបង្ការជម្ងឺផ្តាសាយធំ។ មនុស្សគ្រប់គ្នាដែលមានអាយុចាប់ពី៦ខែឡើងទៅគួរតែទទួលការចាក់ឬំការពារជម្ងឺផ្តាសាយធំ។
នៅពេលដែលមកជួបគ្រូពេទ្យអ្នកលើកក្រោយ, សូរគាត់អំពីឬំចាក់បង្ការរោគផ្តាសាយធំនេះ។ វាមាននៅតាមឱសថស្ថានជាច្រើននៅក្នុងស្រុកដែរ។ គិលានុប្បដ្ឋានៅខាងផ្នែកសុខភាពសាធារណ:ចានចុះទៅតាមសាលាបឋមសិក្សាខ្លះដើម្បីចាក់ឬំការពារនេះដល់សិស្សសាលា។ សូមចង់ចាំថាត្រូវតែប្រាប់ឲ្យគ្រូពេទ្យអ្នកចានដឹង បើសិនជាអ្នកចានចាក់ឬំការពារជម្ងឺផ្តាសាយធំនេះ នៅកន្លែងផ្សេងទៀតក្រៅពីមន្ទីរសុខភាពរបស់យើង។

(ដោយសារឬំបង្ការរោគផ្តាសាយធំប្រភេទចាក្យតាមច្រមុះមានការចុះថយប្រសិទ្ធិភាព, ដូច្នេះវានឹងមិនមាននៅរដូវផ្តាសាយនេះទៀតទេ។)

ដើម្បីការពារខ្លួនអ្នកពីជម្ងឺនេះ ត្រូវលាងដៃរបស់អ្នកជាមួយសាប៊ូ និង ទឹកក្តៅឧណ្ហៗឲ្យចានល្អីកល្អាប់ ជាពិសេសក្រោយពីចេញទៅក្រៅនៅទីកន្លែងសាធារណ: ។



បញ្ឈប់ការរីករាលដាលនៃមេរោគ ដែលធ្វើឲ្យអ្នក និង អ្នកដទៃទៀតឈឺ !

យកក្រដាសជូត គ្របមាត់ និង ច្រមុះ នៅពេលអ្នកក្អក ឬកណ្តាស់។

ក្អក ឬកណ្តាស់ដាក់ដៃអាវផ្នែកខាងលើ, មិនមែនដាក់នៅលើដៃទេ។

ការពង្រីកមន្ទីរពេទ្យធ្មេញក្នុងឆ្នាំ២០១៣

ដោយទន្តពេទ្យ ហ្ជង ឡេ, ជាប្រធានខាងមន្ទីរពេទ្យធ្មេញ

មន្ទីរសុខភាពអាស៊ីនឹងពង្រីកទីកន្លែងសម្រាប់ពេទ្យធ្មេញធំថ្មីមួយទៀត
ដែលនឹងចាប់បើកនៅដើមឆ្នាំ២០១៣។ នៅគ្លីនិកធំរបស់យើង និង វិទ្យាល័យអាឡាមេដា មានការប៉ះពាល់យ៉ាងខ្លាំងដោយសារមានតម្រូវការខ្ពស់។ ដោយសារទីកន្លែងចង្អៀត,
នៅគ្លីនិកធំរបស់យើងមិនអាចទទួលអ្នកជម្ងឺថ្មីបានទេចាប់តាំងពីឆ្នាំ២០១៤មកម្លេះ។ ទោះ ជាយ៉ាងណាក็ដោយ
វិទ្យាល័យអាឡាមេដានៅតែទទួលអ្នកជម្ងឺថ្មីដែលមានលក្ខខណ្ឌតម្រូវឲ្យមានទីលំនៅក្នុងទីក្រុង អាឡាមេដា,
ជាសិស្សវិទ្យាល័យអាឡាមេដា, និងអ្នកចូលរួមក្នុងកម្មវិធី **Head Start** នៅអាឡាមេដា។ រយ:ពេល រង់ចាំនៃការណាត់ជួបជាមធ្យមប្រហែលជា៨ខែសម្រាប់គ្លីនិកទាំងពីរនេះ។ ដោយសារតម្រូវការខ្ពស់ និងទីកន្លែងចង្អៀត,
ដូច្នេះយើងត្រូវការគ្លីនិកថ្មីនេះយ៉ាងខ្លាំង។

មន្ទីរពេទ្យធ្មេញថ្មីនេះនឹងមានទីតាំងនៅផ្លូវកែតគ្នារវាងផ្លូវលេខ១១ និង ផ្លូវចាក់សុន, ជ្ជងផ្លូវពីសាលាបឋមសិក្សាលីង់កុន និងអគាររដ្ឋបាលសន្តិសុខសង្គ័ម។ យើងនឹងមានកន្លែងសម្រាប់ធ្វើធ្មេញចំនួន ៩ និងបន្ទប់ប្រឹក្សាយោបល់១។ យើងនឹងនាំមកនូវបុគ្គលិកពេទ្យធ្មេញថ្មីដើម្បីជួយអ្នកជម្ងឺរបស់យើង។

ការបើកការចុះឈ្មោះសម្រាប់ឆ្នាំ២០១៣ បានមកដល់ហើយ

ដោយវេណសា ហ្ជង ឃ្ជេច ជានាយកនៃសេវាសមាជិក

រយៈពេលនៃការបើកចុះឈ្មោះសម្រាប់ខ្ទមរ៉ាការលីហ្វ័ញ្ញានៅឆ្នាំនេះគឺថ្ងៃទី១ ខែវិច្ឆិកា, ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧។ បើសិនជាអ្នកចង់ទទួលបានធានារ៉ាប់រងសុខភាពដែលនឹងចាប់ផ្តើមពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៧, អ្នកត្រូវតែចុះឈ្មោះឲ្យបានមុនថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦។ ច្បាប់ថែទាំសុខភាពតម្លៃសមរម្យតម្រូវឲ្យមនុស្សភាគច្រើនត្រូវតែមានធានារ៉ាប់រងសុខភាពសាធារណ: ឬឯកជន ឬ "ទទួលខុសត្រូវបង់បំណែកផ្ទាល់ខ្លួន" (បង់ការផ្តាកពិន័យ)។ វាមានសារ:សំខាន់ណាស់សម្រាប់អ្នកជម្ងឺដែលត្រូវតែរក្សាការបន្តធានារ៉ាប់រងសុខភាព។

*មេឌីខែលគឺជាទម្រង់មួយនៃធានារ៉ាប់រងសុខភាពសាធារណ:។ បើសិនជាអ្នកមានសិទ្ធិទទួលមេឌីខែល, អ្នកអាចចុះឈ្មោះពេលណាក็ចាន នៅក្នុងអំឡុងឆ្នាំនេះ។ ទោះជាយ៉ាងណាក็ដោយអ្នកត្រូវតែរក្សាទុកមេឌីខែលរបស់អ្នក, ដោយអ្នកត្រូវតែបំពេញដំណើការត្រួតពិនិត្យ / ការសម្រេច / ការបន្តប្រចាំឆ្នាំដោយ**RRR**។ ខ្ទមរ៉ាការលីហ្វ័ញ្ញាគឺជាធានារ៉ាប់រងសុខភាពនៅទីផ្សាររដ្ឋលីហ្វ័ញ្ញា វាអាចធ្វើឲ្យបុគ្គលម្នាក់។ និងអាជីវកម្មតូចៗទិញធានារ៉ាប់រងសុខភាពឯកជនដោយមានអត្រាប្រាក់ជំនួយពីរដ្ឋាភិបាលសហព័ន្ធ។ ខ្ទមរ៉ាការលីហ្វ័ញ្ញាចានប្រកាសតម្លើងជាមធ្យម ១៣.២ភាគរយនៅទូទាំងរដ្ឋសម្រាប់ផែនការសុខភាពរបស់បុគ្គលនិមួយៗ។នៅទីផ្សារឆ្នាំ២០១៣ ការតម្លើងថ្លៃនេះខ្ពស់ជាងកាលពី២ឆ្នាំកន្លងមក។ ទោះជាយ៉ាងណាក็ដោយការបើកចុះឈ្មោះកាលពីឆ្នាំកន្លងមកនេះ, យើងចានជួយមនុស្សជាច្រើនដោយប្រើមធ្យោបាយសួរតម្លៃ និងប្រៀបធៀប, ដែលអាចជួយកំណត់ការជ្រើសរើសតម្លៃសមស្របជូនអតិថិជនម្នាក់ៗ។ ដូចពីមុនដែរ, បុគ្គលិករបស់យើងនឹងធ្វើការជាមួយអ្នកកឲ្យឃើញជម្រើសសមស្រប ដើម្បីបំពេញតម្រូវការ របស់លោកអ្នក។*

យើងចង់ជួយដើម្បីឲ្យអ្នកចានបន្តមេឌីខែលរបស់អ្នក ឬ សួរតម្លៃធានារ៉ាប់រងឯកជនដែលមានតម្លៃសមស្រប។ ពេលម៉ោងធ្វើការរបស់ការិយាល័យយើងគឺចាប់ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ពីម៉ោង៩ព្រឹក ដល់ម៉ោង៥ល្ងាច, និងថ្ងៃសៅរ៍ពីម៉ោង៩ព្រឹក ដល់ម៉ោង១រសៀល។ សូមទូរស័ព្ទមកយើងដែលមានលេខ (៥១០)-៩៨៦-៦៤០០ ដើម្បីធ្វើការណាត់ជួបជាមួយបុគ្គលិករបស់យើងឲ្យចានមុនពេលជុតកំណត់។

ហេតុអ្វីបានជាយើងទាំងអស់គ្នាគួរតែបោះឆ្នោតនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៦

ដោយបណ្ឌិត ធូ ឃ្ជេច, ជានាយកសុខភាពសហគមន៍ និង ការស្រាវជ្រាវ

នៅសហរដ្ឋអាមេរិកមានកំណើនយ៉ាងចាប់រហ័សនៃក្រុមពួជសាសន៍អាស៊ីអាមេរិកាំង និង ជនជាតិដែលរស់នៅលើកោះអាស៊ីចាស៊ីហ្វิក។ យើងអាចមានឥទ្ធិពលលើសង្គម ជាពិសេសបើយើងប្រើសិទ្ធិអំណាចតាមរយៈការចុះឈ្មោះរបស់យើង។ ពេលយើងចុះឈ្មោះ, យើងអាច: ១) មានឥទ្ធិពលលើតំណែងរបស់ក្រុមមន្ត្រីដែលជាប់ឆ្នោតនៅក្នុងរដ្ឋាភិបាល, ២) ជំរុញឲ្យក្រុមមន្ត្រីដែលជាប់ឆ្នោតយកចិត្តទុកដាក់ទៅនឹងតម្រូវការនៃជនជាតិអាស៊ីអាមេរិកាំង និង ជនជាតិដែលរស់នៅលើកោះអាស៊ីចាស៊ីហ្វิក,និង ៣) ជួយមានឥទ្ធិពលលើច្បាប់ដែលត្រូវអនុម័តដែលអាចប៉ះពាល់ដល់សហគមន៍របស់យើង។ ដើម្បីមានសិទ្ធិចុះឈ្មោះតម្លៃត្រូវតែមានសញ្ជាតិអាមេរិកាំង និងមានអាយុយ៉ាងតិច ១៨ឆ្នាំ។ ហើយអ្នកត្រូវតែចុះឈ្មោះចុះឈ្មោះឲ្យចានមុនថ្ងៃទី២៤ខែតុលា ឆ្នាំ២០១៦ ដើម្បីអាចចានចូលរួមចុះឈ្មោះនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៦។ ក្រោយពីចានចុះឈ្មោះចុះឈ្មោះ, អ្នកនៅតែជាអ្នកចុះឈ្មោះចុះឈ្មោះ, ប៉ុន្តែបើអ្នកប្តូរអាស័យដ្ឋាន និងព៌ាតមានដែលអាចទាក់ទងចាន អ្នកអាចនឹងត្រូវចុះឈ្មោះជាថ្មី ជាមួយនិងព៌ាតមានថ្មីរបស់អ្នក។

អ្នកអាចចុះឈ្មោះដោយធ្វើរសន្ទឹកឈ្មោះតាមប៉ុស្តិ៍ប្រៃសណីយ៍ (តាមរយៈការចុះឈ្មោះដោយមិនមានវត្តមាន) ឬទៅស្តានឌីយ៉ូចុះឈ្មោះដែលចានកំណត់ទុកជាមុនរបស់អ្នកដើម្បីចុះឈ្មោះ។ មានឯកសារណែនាំផ្សេងៗទៀត បើសិនជាអ្នកចង់រៀនបន្ថែមអំពីអ្វីដែលមាននៅលើសន្ទឹកឈ្មោះ។ បើសិនជាអ្នកត្រូវការជំនួយខាងភាសា, ច្បាប់រដ្ឋចានចែងថាអ្នកអាចនាំមនុស្សម្នាក់ឬពីរនាក់ចូលក្នុងបន្ទប់ចុះឈ្មោះចាន ឬអ្នកអាចនឹងស្នើសុំជំនួយពីបុគ្គលិកកន្លែងចុះឈ្មោះដែលនិយាយពីភាសា។

មិនគិតថាតើអ្នកធ្វើដូចម្តេចទេ, វាជាការសំខាន់សម្រាប់សម្លេងអ្នកដែលនឹងត្រូវចានឮ/ វាជាសិទ្ធិក្នុងការចុះឈ្មោះរបស់អ្នកដែលជាពលរដ្ឋអាមេរិក, ដូច្នេះសូមប្រើសិទ្ធិរបស់អ្នក។